**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០២៥

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកប ដោយស្មារតីទទួលខុសត្រូវខ្ពស់ ទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារធំ៥

### ១-មុខងារនីតិកម្ម

- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា និងពិនិត្យសម្រេចលើសំណើរបស់គណៈកម្មការជំនាញ លើសេចក្តីព្រាងច្បាប់ ចំនួន ២ច្បាប់។
- បានរៀបចំបើកសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ដែលមានរបៀបវារៈដូចខាងក្រោម៖
  - ១-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និង
  - ២-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក។

### ២-មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា រួមមាន៖
  - ❖ គណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ពីការអនុវត្តច្បាប់ ការដោះស្រាយពាក្យបណ្តឹងរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ នៅខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

❖ គណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយផ្ដោតលើថវិកាថ្នាក់ក្រោមជាតិអំពីបញ្ហាប្រឈម និងសំណូមពរ នៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។

❖ គណៈកម្មការទី៣ព្រឹទ្ធសភា បានយាង និងអញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តព្រះសីហនុ ដើម្បីសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៣ព្រឹទ្ធសភា នៅខេត្តព្រះសីហនុ។

❖ គណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះបេសកកម្ម ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានអំពីការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង។

❖ គណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ស្ដីពី វឌ្ឍនភាពការងារ បញ្ហាប្រឈម និងផែនការសកម្មភាពក្នុងពេលខាងមុខ នៅទីស្ដីការក្រសួង និងទីស្ដីការរដ្ឋលេខាធិការដ្ឋាន និង

❖ គណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយអង្គភាពប្រឆាំងអំពើពុករលួយ នៅទីស្ដីការអង្គភាពប្រឆាំងអំពើពុករលួយ និងបានអញ្ជើញចុះបំពេញបេសកកម្មដើម្បីឈ្វេងយល់ស្ដីពី ប្រសិទ្ធភាព និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្ដីពី ការប្រឆាំងអំពើពុករលួយ និងវឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តតាកែវ និងខេត្តព្រៃវែង។

## ៣-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖

❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីនានា នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា ចំនួន២លើក រួមមាន៖

- បានអញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ស្ដេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីសម្ពោធមហាកុដិសម្ដេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានា នៅវត្តឧណ្ណាលោម ខណ្ឌដូនពេញ រាជធានីភ្នំពេញ និង
- បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធអគារសិក្សា និងសមិទ្ធផលនានា ក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ នៅភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភាបាន៖

- អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំនានា ចំនួន៤លើក៖
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និង សម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន១លើក និង
  - បានអញ្ជើញសំណេះសំណាលជាមួយ **ឯកឧត្តម លោកជំទាវ** ជាទីប្រឹក្សាឯកឧត្តម អនុប្រធានទី១ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- សកម្មភាពចុះមូលដ្ឋាន៖
  - បានណែនាំ និងចាត់ **ឯកឧត្តម ឡាន់ ឆន** អនុប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌របស់សាធារណរដ្ឋបារាំង នៅកម្ពុជា (AMH) អញ្ជើញចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅមន្ទីរពេទ្យបង្អែកព្រះនរោត្តមសីហនុ និងមន្ទីរពេទ្យបង្អែកស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។
  - បានណែនាំ និងចាត់ **ឯកឧត្តម មាស ជេត** និង**ឯកឧត្តម នេត សេរី** ទីប្រឹក្សារបស់ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញចុះពិនិត្យស្ថានភាពជាក់ស្តែង និងដំណើរការជួសជុលសាលាធម្មសភា នៅក្នុងសីមាវត្តជ្រៃបិតមាស ក្រុងសួង ខេត្តត្បូងឃ្មុំ។
  - បានអញ្ជើញចុះជួបសំណេះសំណាល ចំនួន៣លើក ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្មៀន នាយប៉ុស្តិ៍នគរបាល ប្រធានមណ្ឌលសុខភាព ទូទាំងក្រុងសួង ស្រុកអូររាំងឪ និងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ សរុបចំនួន២៩៧នាក់។ ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា បាននាំយកអំណោយជាឱសថ ចំនួន១២មុខ សរុបស្មើនឹង៨៥៦កេស និងម៉ាស៊ីនជំនួយអុកស៊ីសែន ចំនួន១២គ្រឿង ដែលជាអំណោយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េ ជូនដល់មន្ទីរពេទ្យបង្អែក ចំនួន៩ ក្នុងខេត្តត្បូងឃ្មុំ និង ខេត្តកំពង់ចាម សម្រាប់ប្រើប្រាស់សំដៅរួមចំណែកដល់ការអភិវឌ្ឍវិស័យសុខាភិបាល និងសុខុមាលភាពប្រជាជន និង
  - បានណែនាំ និងចាត់ក្រុមទីប្រឹក្សារបស់ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** និង មន្ត្រីខុទ្ទកាល័យ ដឹកនាំដោយ **ឯកឧត្តម តាន់ វុដ្ឋា** ជូនដំណើរ **លោកវេជ្ជបណ្ឌិត ហ្វីលីប ពើរ៉ូចេត** (Philippe Peruchet) តំណាងក្រុមហ៊ុន Laboratoire Bioderma មកពីសាធារណរដ្ឋបារាំង ដើម្បីចុះជួបពិភាក្សាជាមួយមន្ត្រីសុខាភិបាល និងអាជ្ញាធរពាក់ព័ន្ធ នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីសម្ពោធមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានា

ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធអគារសិក្សា និងសមិទ្ធផលនានា ក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។
- បានអញ្ជើញជូន និងទទួលដំណើររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង
- បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការរវាងគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតនៃព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ទឡ្ហនា** អនុប្រធានទី២ព្រឹទ្ធសភាបាន៖

- អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំនានា រួមមាន៖
  - បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន១លើក និង
  - បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយប្រធានគណៈកម្មការទាំង១០នៃព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំវេទិកាពាក់ព័ន្ធនឹងវិស័យផ្សេងៗ រៀបចំផែនការប្រចាំឆ្នាំ និងប្រចាំនីតិកាល និងបញ្ហាផ្សេងៗ។
- សកម្មភាពចុះមូលដ្ឋាន៖
  - បានអញ្ជើញចុះជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ សរុបចំនួន១៨០នាក់ មកពី៣៩សង្កាត់នៃខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌកំបូល ខណ្ឌសែនសុខ និងខណ្ឌមានជ័យ។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីសម្ពោធមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានា ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធអគារសិក្សា និងសមិទ្ធផលនានា ក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។
- បានអញ្ជើញជូន និងទទួលដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
- បានអញ្ជើញនាំយកសម្ភារសិក្សា កង់ និងទូរទស្សន៍ ចែកជូនដល់សិស្សានុសិស្ស នៅសាលាបឋមសិក្សាអាត់ស៊ូ និងសាលាបឋមសិក្សាកូនក្អែក នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ និង
- បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សា ១ខ្នង មាន៣បន្ទប់ និងសមិទ្ធផលនានា នៅសាលាបឋមសិក្សាមិល ស្រុកស្នួល ខេត្តក្រចេះ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីសម្ពោធមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានា ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារសិក្សា និងសមិទ្ធផលនានា ក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។
- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ដើម្បីពិភាក្សាអំពីការរៀបចំវេទិកាពាក់ព័ន្ធនឹងវិស័យផ្សេងៗ និងការរៀបចំផែនការប្រចាំឆ្នាំ និងប្រចាំនីតិកាល នៅសាលប្រជុំពិសេស៣ ព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធអគារសិក្សា ១ខ្នង ជាអំណោយអង្គការសប្បុរសជនជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៅសាលាបឋមសិក្សាមិល ស្រុកស្នួល ខេត្តក្រចេះ។
- បានអញ្ជើញចូលរួមប្រជុំក្រុមសមាជិកសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅវិមាន៧មករា។

- បានអញ្ជើញចូលរួមក្នុងពិធីប្រកាសទទួលស្គាល់សមាសភាពរបស់គណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។
- បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីផ្សព្វផ្សាយខ្លឹមសារអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣២ ក្រោមអធិបតីភាពរបស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំធំសាកលវិទ្យាល័យស្វាយរៀង។
- បានអញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី " សេចក្តីប្រកាសនយោបាយក្រោយកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិស្តីពី ជំងឺរបេង (UNHLM-TB) និងរបាយការណ៍ស្តីពី អភិបាលកិច្ចជំងឺរបេងឆ្នាំ២០២៤" នៅសណ្ឋាគារអេនីកផាលេសភ្នំពេញ។
- បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌របស់សាធារណរដ្ឋបារាំង នៅកម្ពុជា (AMH) ចុះពិនិត្យព្យាបាលជំងឺ ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។
- បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCAsia) និងអង្គភាពដៃគូនានា ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា ដើម្បីពិភាក្សាការងារស្តីពី ការគ្រប់គ្រង និងការអភិរក្សដីសមូហភាពរបស់ជនជាតិដើមភាគតិច និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ **ចំនួន៣លើក** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជារួមមាន៖

  ១/ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងាររយៈពេល៥ឆ្នាំ ២០២០-២០២៤ នៃដំណើរឆ្ពោះទៅបរិវត្តកម្មឌីជីថល និងទិសដៅការងារបន្ត របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

  ២/ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និង

  ៣/ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២៣-២០២៤ នៅរាជធានីភ្នំពេញ។

❖ ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ

ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្តាខេត្តនានា **ចំនួន៩៥លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន៨៥លើក**។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន១លើក។
- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធអគារសិក្សា និងសមិទ្ធផលនានា ក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ នៅភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។
- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញចូលរួមជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងព្រះរាជពិធីសម្ពោធមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានា ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមកិច្ចប្រជុំត្រៀមរៀបចំព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាមន្ត្រី គុយ សុផល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នៅសាលប្រជុំក្រសួងព្រះបរមរាជវាំង និង
- ទទួលជួប **ឯកឧត្តមបណ្ឌិត គឹម រុនស៊ីណារិទ្ធិ** នាយកខុទ្ទកាល័យអនុប្រធានទី២ព្រឹទ្ធសភា និងសហការី ដើម្បីពិភាក្សាអំពីសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ និងស្នើសុំអនុសាសន៍ស្តីពីកិច្ចការការទូត។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក បូ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញជូន និងទទួលដំណើររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- អញ្ជើញចូលរួមក្នុងពិធីសម្ពោធអគារសិក្សា និងសមិទ្ធផលនានា ក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។
- អញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងគណៈកម្មការទី១ព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់

របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើងវិមានព្រឹទ្ធសភា និង

- អញ្ជើញចូលរួមពិធីសំណេះសំណាលរវាងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាននៃខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌកំបូល ខណ្ឌសែនសុខ និងខណ្ឌមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅសាលប្រជុំសាលាខណ្ឌដង្កោ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបានៈ

- អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន១លើក និង
- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៤លើក។

❖ **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៣លើក។

❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបានៈ

- អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌កម្ពុជារបស់សាធារណរដ្ឋបារាំង នៅកម្ពុជា (AMH) ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៣លើក។

❖ សមាជិក-សមាជិកាសហភាពសហព័ន្ធយុវជនកម្ពុជានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៣០រូប បានអញ្ជើញចូលរួមបរិច្ចាគឈាម ក្រោមប្រធានបទ "យើងរួមគ្នាបរិច្ចាគឈាម ១,០០០សាក់ ដើម្បីសង្គ្រោះជីវិត" នៅមជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសនៃពិធីចម្រើនជន្មាយុ គោរពជូនៈ

  - **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
  - **ឯកឧត្តម កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជាតំណាងរាស្ត្រមណ្ឌលខេត្តបន្ទាយមានជ័យ។
  - **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា។
  - **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង
  - **ឯកឧត្តម វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

- បានរៀបចំទេយ្យវត្ថុសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃ ចំនួន៨០កញ្ចប់ ក្នុងពិធីបុណ្យមាឃបូជា និង
- បានទទួលពាក្យបណ្ដឹង ចំនួន១៨បណ្ដឹង បញ្ជូនពាក្យបណ្ដឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធ ចំនួន៧បណ្ដឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធ ចំនួន២បណ្ដឹង កំពុងពិនិត្យសិក្សា ចំនួន១៩បណ្ដឹង ផ្ដល់ព័ត៌មានទៅម្ចាស់បណ្ដឹង ចំនួន៧បណ្ដឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន៨បណ្ដឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖
  - ❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិចូលជួបសម្ដែងការគួរសម នៅវិមានព្រឹទ្ធសភា និងវិមាន៧មករា ចំនួន៦លើក រួមមាន៖
    - **លោកជំទាវ ម៉ាតា ម៉ាត្រៃ** ( Marta Martrai ) អនុប្រធានទី១ នៃសភាជាតិហុងគ្រី។
    - **ឯកឧត្តម គីម ជីនព្យូ** ( Kim Jin-Pyo ) អតីតប្រធានរដ្ឋសភានៃសាធារណរដ្ឋកូរ៉េ និងជាប្រធានក្រុមប្រឹក្សាអង្គការដើម្បីពិភពលោកទាំងអស់គ្នា ( Global Together )។
    - **ឯកឧត្តម យីង លី** ( Yin Li ) សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន និងជាលេខាធិការគណៈកម្មាធិការបក្សកុម្មុយនីស្តចិន ប្រចាំរដ្ឋធានីប៉េកាំង។
    - **ឯកឧត្តម ង្វៀន មិញវូ** ( Nguyen Minh Vu ) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
    - **លោក អេឌី ពីរ៉ាដ** ( Eddy Pirard ) អគ្គនាយក និងជានាយកប្រតិបត្តិ ( CEO ) នៃក្រុមហ៊ុន Japan Tobacco International ( JTI ) សកលលោក និង
    - **លោកសាស្ត្រាចារ្យ តេតស៊ូយ៉ា វ៉ាតាណាបេ** ( Tetsuya Watanabe ) និងគណៈប្រតិភូវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់កិច្ចការអាស៊ាន និងអាស៊ីបូព៌ា ( ERIA )។
  - ❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចផ្លូវការ ចំនួន២លើក រួមមាន៖

    ១-អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដោយនៅក្នុងឱកាសនោះ **សម្ដេចតេជោ** បានអញ្ជើញជួបពិភាក្សាការងារ និងចូលរួមពិធីផ្សេងៗ **ចំនួន៥លើក** រួមមាន៖
    - **ឯកឧត្តមបណ្ឌិត សៃស៊ុមផន កុមវិហាន** ប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅវិមានរដ្ឋសភាជាតិឡាវ។
    - **ឯកឧត្តម សនសៃ ស៊ីផាន់ដន** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅការិយាល័យនាយករដ្ឋមន្ត្រីឡាវ។
    - អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅស្តូបអនុស្សាវរីយ៍វីរជនពលី។
    - អញ្ជើញទស្សនាអគារវិមានរដ្ឋសភាជាតិឡាវ និងអញ្ជើញដាំដើមឈើជាអនុស្សាវរីយ៍ និង
    - អញ្ជើញចូលរួមពិធីលៀងសាយភោជន៍ផ្លូវការ ដែលរៀបចំដោយ **ឯកឧត្តមបណ្ឌិត សៃស៊ុមផន កុមវិហាន** ប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅសណ្ឋាគារហ្វូលីដេអ៊ីន។

២-អញ្ជើញចូលរួមកិច្ចប្រជុំកំពូលបក្សរវាង កម្ពុជា-វៀតណាម និងរវាង កម្ពុជា-ឡាវ-វៀតណាម នៅទីក្រុងហូជីមិញនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយនៅក្នុងឱកាសនោះ **សម្តេចតេជោ** បានអញ្ជើញជួបពិភាក្សាការងារ ចំនួន២លើក រួមមាន៖

- **ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម និង
- **ឯកឧត្តម ថងលុន ស៊ីសុលីត** អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ។

❖ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភាបាន៖

- ទទួលរៀបចំអាហារពេលព្រឹកការងារជាមួយ **លោកជំទាវ ប្រៃហ្គេត អិល វ៉កឃឺ** (Bridgette L. Walker) ភារធារីស្តីទីនៃស្ថានឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា និង
- អញ្ជើញចូលរួមពិធីជប់លៀង នៅនិវេសនដ្ឋានរបស់ឯកអគ្គរដ្ឋទូតរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធុនា** អនុប្រធានទី២ព្រឹទ្ធសភាបាន៖

- អនុញ្ញាតឱ្យគណៈប្រតិភូជប៉ុន ដឹកនាំដោយ **លោក អាស៊ូស៊ី ណារូស** (Atsushi Naruse) អភិបាលក្រុង Kota ប្រទេសជប៉ុន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារទាក់ទងនឹងការពង្រឹងទំនាក់ទំនងការទូត កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អប់រំ សុខាភិបាល និងការផ្លាស់ប្តូរប្រជាជន និងប្រជាជន។
- អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងជំនួបពិភាក្សាការងាររវាងគណៈប្រតិភូព្រឹទ្ធសភា ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ជាមួយគណៈប្រតិភូកូរ៉េនៃវិទ្យាស្ថានបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ (DIST) ដឹកនាំដោយ **លោក លី ជូន ហ៊ីយ៉ាន់** (Lee Jun Hyan) ប្រធាននាយកដ្ឋានក្រុមហ៊ុន DIST IUC ដើម្បីស្វែងរកដៃគូអភិវឌ្ឍន៍ទាក់ទងនឹងវិស័យកសិកម្ម (កម្មវិធី SMART FARM) នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាបុណ្យជាតិអូស្ត្រាលី ឆ្នាំ២០២៥ ដែលរៀបចំដោយ **ឯកឧត្តម ដេរិក យីប** (Derek Yip) ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតអូស្ត្រាលី រាជធានីភ្នំពេញ និង
- អញ្ជើញចូលរួមកម្មវិធី Charity Gala Dinner។

❖ **ឯកឧត្តម ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី ប្រតិបត្តិការរវាងគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតនៃព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមកិច្ចប្រជុំនៃមហាសន្និបាតលើកទី១៥ នៃសភាតំបន់អាស៊ី APA នៅទីក្រុងបាគូ ប្រទេសអាស៊ែបៃហ្សង់ និង

- អញ្ជើញចូលរួមពិសាអាហារពេលព្រឹកជាមួយ **លោកស្រី ប្រែហ្គេត អែល វ៉កឃឺ** (Bridgette L.Walker) ភារធារីស្តីទីនៃស្ថានទូតសហរដ្ឋអាម៉េរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

❖ **ឯកឧត្តម ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា **ឯកឧត្តម គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា **លោកជំទាវបណ្ឌិត អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា និង**សម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាង និងអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមរៀបចំការប្រជុំប្រចាំឆ្នាំរបស់ក្រុមអ្នកនយោបាយអាយប៉ា(AIPA) លើកទី១៦ នៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពរបស់ **ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** ប្រធានស្តីទីរដ្ឋសភា និងជាប្រធានក្រុមអាយប៉ាជាតិកម្ពុជា នៅវិមានរដ្ឋសភា។

❖ **លោកជំទាវ មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និង**ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានចូលរួមជាមួយគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ដឹកនាំដោយ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅរដ្ឋធានីហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

❖ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបាន៖

- អញ្ជើញជួបពិភាក្សាការងារជាមួយគណៈប្រតិភូជប៉ុន ដឹកនាំដោយ **លោក ហ្វូជី តូរូ** (Fu Jie Toru) ប្រធានសភាក្រុងកូតា អញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់ និងដាក់ទុនវិនិយោគលើវិស័យកសិកម្ម និងកសិ-ទេសចរណ៍ នៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅខេត្តកំពង់ស្ពឺ និង
- អញ្ជើញដឹកនាំគណៈប្រតិភូទៅទស្សនកិច្ចសិក្សាឈ្វេងយល់ពីរោងចក្រផលិតជីសរីរាង្គ និងទស្សនកិច្ចតំបន់កសិកម្ម កសិ-ឧស្សាហកម្ម នៅខេត្តសានដុងនៃសាធារណរដ្ឋប្រជាមានិតចិន។

❖ **ឯកឧត្តមបណ្ឌិត នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និង**ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបាន៖

- អញ្ជើញអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាបុណ្យជាតិអូស្ត្រាលី ឆ្នាំ២០២៥ ដែលរៀបចំដោយ **ឯកឧត្តម ដេរិក យីប** (Derek Yip) ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតអូស្ត្រាលី រាជធានីភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និង**ឯកឧត្តម សួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥រដ្ឋសភា បានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារ

ជាមួយ **ឯកឧត្តម ឡូរ៉ង់ វ៉ឺលី** (Laurent Wehrli) ប្រធានគណៈកម្មាធិការគោលនយោបាយការបរទេសនៃក្រុមប្រឹក្សាជាតិនៃប្រទេសស្វីស នៅសណ្ឋាគារ Raffles Hotel Le Royal រាជធានីភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបាន៖

- អនុញ្ញាតឱ្យ **លោកស្រី អេនជេឡា កូរកូរេន** (Angela Corcoran) ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារក្នុងឱកាសដែលលោកស្រីអញ្ជើញបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា។
- អនុញ្ញាតឱ្យ **លោក ខៀវ កូលា** អគ្គនាយករងទទួលបន្ទុកព័ត៌មាននៃទូរទស្សន៍ CNC ចូលជួបសម្តែងការគួរសម និងសួរសុខទុក្ខ នៅការិយាល័យឯកឧត្តមបណ្ឌិតប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា។
- អញ្ជើញចូលរួមកិច្ចប្រជុំចង្អៀតត្រៀមរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ ដឹកនាំដោយ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការជាតិរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ឆ្នាំ២០២៦ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
- អញ្ជើញចូលរួមកម្មវិធីខួបលើកទី៧៥ នៃការបង្កើតទំនាក់ទំនងទ្វេភាគីរវាងសហរដ្ឋអាម៉េរិក និងព្រះរាជាណាចក្រកម្ពុជា ដោយមានការចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅសារមន្ទីរជាតិកម្ពុជា រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងកម្មវិធីខួបលើកទី៦ របស់វិទ្យាស្ថានចក្ខុវិស័យអាស៊ី និងកម្មវិធីពិសេសស្តីពី ការសម្ពោធសៀវភៅ ក្នុងនោះមានរៀបចំវេទិកាពិភាក្សា ក្រោមប្រធានបទ " គោលនយោបាយការបរទេសកម្ពុជាក្នុងយុគសម័យថ្មី " និងកម្មវិធីពិសេសស្តីពី ការដាក់សម្ពោធសៀវភៅ "អាស៊ាន និងទំនួលខុសត្រូវក្នុងការការពារ ASEAN and Responsibility to Protect (R2P)៖ ទំនាក់ទំនងដែលមានភាពស្រពេចស្រពិល " ដោយអ្នកនិពន្ធ **បណ្ឌិត នេត ជីតាច័ន្ទជីម៉ា** នៅសណ្ឋាគារហៃយ៉ាត់រីជិនស៊ី រាជធានីភ្នំពេញ
- អញ្ជើញចូលរួមពិធីជប់លៀងកុកតែលក្នុងឱកាសទិវាអ្នកការទូតសហព័ន្ធរុស្ស៊ី នៅនិវេសនដ្ឋានឯកអគ្គរដ្ឋទូតរុស្ស៊ី រាជធានីភ្នំពេញ និង
- អញ្ជើញចូលរួមកម្មវិធីបើកនៃបុណ្យ KIZUNA ២០២៥ នៅអគារ CJCC សាកលវិទ្យាល័យភូមិន្ទភ្នំពេញ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមអបអរសាទរពិធីបុណ្យចម្រើនព្រះជន្មព្រះចៅអធិរាជជប៉ុន នៅស្ថានទូតជប៉ុនប្រចាំកម្ពុជា។

❖ **ឯកឧត្តម អ៊ុំ សារិទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃបណ្តាញហ្វ្រង់កូហ្វូនសីលធម៌ និងក្រុមសីលធម៌សមាជិកសភា

ដើម្បីពិភាក្សាអំពីការផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការអេចិន្ត្រៃយ៍សម្រាប់ឆ្នាំ២០២៥ តាមប្រព័ន្ធនិម្មិត (Video Conference) នៅសាលប្រជុំពិសេសកណ្តាលព្រឹទ្ធសភា និង

❖ **សម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបាន៖
  - យាងជាកិត្តិយសក្នុងពិធីលៀងសាយភោជន៍ ដែលរៀបចំដោយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** (UENO Atsushi) ឯកអគ្គរដ្ឋទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតជប៉ុន រាជធានីភ្នំពេញ និង
  - យាងដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយ តម្រង់ទិសដល់និស្សិតអាហារូបករណ៍មូលនិធិមុទិតា និងចែករំលែកបទពិសោធន៍អំពីការត្រៀមខ្លួនទៅសិក្សាបន្តនៅសាធារណរដ្ឋប្រជាមានិតចិន នៅគ្រឹះស្ថានមូលនិធិមុទិតា រាជធានីភ្នំពេញ។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដោយនៅក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា** បានអញ្ជើញចូលរួមអម **សម្តេចតេជោ** ក្នុងជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំឡាវ ចំនួន៣លើក។
  - អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិនានា នៅវិមានព្រឹទ្ធសភា និងវិមាន៧មករា ចំនួន៥លើក។
  - អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ទទួលជួបពិភាក្សាការងារ និងពិសាអាហារពេលល្ងាចជាមួយ **ឯកឧត្តម យីង លី** (Yin Li) សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន និងលេខាធិការគណៈកម្មាធិការបក្សកុម្មុយនីស្តចិន ប្រចាំរដ្ឋធានីប៉េកាំង នៅវិមាន៧មករា រាជធានីភ្នំពេញ។
  - ទទួលជួបពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិ ចំនួន២លើក រួមមាន៖
    - **ឯកឧត្តម អ៊ីហ្គ័រ ការ៉ាវ៉ាវ** (Igor Karavaev) អគ្គទីប្រឹក្សានៃស្ថានទូតរុស្ស៊ីប្រចាំកម្ពុជា ដើម្បីពិភាក្សាការងារ និងផ្លាស់ប្តូរយោបល់លើកិច្ចសហប្រតិបត្តិការនានា ដែលជាផលប្រយោជន៍រួម និងត្រៀមលក្ខណៈរៀបចំការផ្លាស់ប្តូរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំនៃស្ថាប័នទាំងពីរនាពេលខាងមុខ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា និង
    - **ឯកឧត្តម អឺមេនេជីលដូ កូប៉ា ឡូប៉េស** (Ermenegildo Kupa Lopes) ឯកអគ្គរដ្ឋទូតទីម័រឡេស្តេ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារ និងផ្លាស់ប្តូរយោបល់លើកិច្ចសហប្រតិបត្តិការនានា ដែលជាផលប្រយោជន៍រួមរវាងស្ថាប័នទាំងពីរ និងអំពីការរៀបចំទស្សនកិច្ចផ្លូវការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នាពេលខាងមុខ។

- បានចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរគុណរបស់ **ឯកឧត្តម ស៊ី ជីនពីង** (Xi Jinping) ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្ញើសារលិខិតចូលរួមរំលែកទុក្ខជូន **ឯកឧត្តម** ចំពោះគ្រោះធម្មជាតិរញ្ជួយដី នៅតំបន់ស្វយ័តស៊ីជាំង ភាគនិរតីនៃសាធារណរដ្ឋប្រជាមានិតចិន និង
- បានសហការ និងទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ក្រៅប្រទេស បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា(CADT) មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) និងក្រសួង ស្ថាប័ននានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកភ្ញៀវគេរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
    - អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង
    - អញ្ជើញជាអធិបតីក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី " វប្បធម៌រដ្ឋបាល វប្បធម៌សភា និងវប្បធម៌នយោបាយ " នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- **ឯកឧត្តម អោក ប៊ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីដេញថ្លៃស្តីពីការផ្គត់ផ្គង់ប្រេងឥន្ធនៈរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ឆ្នាំ២០២៥ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។

### ៥.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

- បានបើកប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារបន្ថែម ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺ ប្រាក់ឧបត្ថម្ភធ្វើដំណើរ និងសេវាទំនាក់ទំនងប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមរយៈប្រព័ន្ធធនាគារ។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥។
- បានផ្សព្វផ្សាយបន្តការបង់ភាគទានសមាគមសង្គហៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិមូលដ្ឋាន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ឆ្នាំ២០២៥ និងបានទទួលភាគទានពីសមាជិកព្រឹទ្ធសភា ដើម្បីបង់ជូនសមាគម។
- បានស្នើសុំបុរេប្រទាន និងឥណទានបន្ថែម សម្រាប់ចំណាយលើបេសកកម្មក្រៅប្រទេសរបស់គណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា ដឹកនាំដោយ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៥៥សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន៧១សំណើ។
- បានដោះស្រាយសំណើផ្សេងៗ និងផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា កម្មវិធីផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣៧សំណើ។
- បានថតចម្លងឯកសារ ចំនួន២,៥២៤ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន១២,៧១០សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តទាំង៨ភូមិភាគ ចំនួន៨៥លើក ស្មើនឹង២៥៥នាក់។
- បានរៀបចំ បោសសម្អាត តុបតែងលម្អសាល តាំងលម្អផ្កាមុខអគារក្រហម និងសាលជំនួបភ្ញៀវ ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន១៣លើក ស្មើនឹង៥៤៥នាក់។
- បានទទួលលិខិតចូល ចំនួន៣២០ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង ស្ថាប័នពាក់ព័ន្ធនានា ចំនួន៥៩៩ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៥៦ច្បាប់ ស្មើនឹង៣០៥នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៥ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងខេត្តកំពត ចំនួន១០នាក់។
- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន២៥លើក ព្រមទាំងបានសម្អាតបរិស្ថាន អនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ រួមមាន៖
  - មន្ត្រីរាជការក្របខ័ណ្ឌ ចំនួន៧១៩នាក់ (ប្រុស៤២៦នាក់ ស្រី២៩៣នាក់)។
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៨៤នាក់ (ប្រុស៤៩នាក់ ស្រី៣៥នាក់)។
  - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៥នាក់ (ប្រុស៣០៨នាក់ ស្រី១៨៧នាក់)។
  - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន១២នាក់ និង
  - មន្ត្រីរាជការព្យួរនៅក្រៅក្របខ័ណ្ឌដើម ចំនួន៥នាក់។
- បានធ្វើសេចក្តីសម្រេច ចំនួន១៧ច្បាប់ និងលិខិតបង្គាប់ការ ចំនួន២ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្គត់ផ្គង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៨ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ ( ប្រពន្ធ ចំនួន១នាក់ និងកូន ចំនួន១នាក់) ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥។
- បានរៀបចំផ្សព្វផ្សាយអំពីការធ្វើបច្ចុប្បន្នភាពព័ត៌មានជីវប្រវត្តិមន្ត្រីរាជការក្របខ័ណ្ឌនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤នាក់ ចូលរួមវគ្គបណ្តុះបណ្តាល នៅក្នុងប្រទេស ចំនួន២វគ្គ ស្តីពី៖
  - វិក្រឹតការមន្ត្រីជាន់ខ្ពស់ សម្រាប់ឆ្នាំ២០២៥ នៅសាលាភូមិន្ទរដ្ឋបាល និង
  - ភាសាចិនកម្រិត HSK2 នៅវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២នាក់ ចូលរួមវគ្គបណ្តុះបណ្តាល នៅក្រៅប្រទេស ចំនួន១វគ្គ ស្តីពី " ការវិភាគសារពើពន្ធ និរន្តរភាពហិរញ្ញវត្ថុ និងការគណនា គោលនយោបាយ " នៅសាធារណរដ្ឋកូរ៉េ។
- បានតាមដាន និងចូលរួមយកចិត្តទុកដាក់ក្នុងដំណើរការកសាងអគារថ្មី ព្រមទាំងការងារសាងសង់ ជួសជុល កែលម្អអគារ លើកកម្ពស់បរិស្ថាន អនាម័យ ឱ្យបានស្អាត និងស្រស់បំព្រង ជាពិសេស ការងារសន្តិសុខ សណ្តាប់ធ្នាប់ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានសុខសុវត្ថិភាពគ្រប់ពេលវេលា។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ រួមមាន៖
  - បានខាត់ លាបផ្លូវដើរ នៅខាងមុខសាលប្រជុំពេញអង្គព្រឹទ្ធសភា។
  - បានជួសជុលចង្អូរទឹកមុខជណ្តើរយន្ត នៅអគារក្រហមព្រឹទ្ធសភា។
  - បានជួសជុលទ្វារឈើក្បាច់ និងបំពាក់ដែកឆក់នៅខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ចំនួន១៤គ្រឿង។
  - បានធ្វើស្លាកឈ្មោះថ្មី នៅបន្ទប់សមាជិកព្រឹទ្ធសភា និងបិទក្រដាសជញ្ជាំង នៅបន្ទប់ ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា និង
  - បានជួសជុលម៉ូទ័រទ្វារ និងប្តូរតេឡេម៉ូទ័រថ្មី នៅច្រកចេញ-ចូល P1។
- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្ត កំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូល សម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ ប្រគល់ និងបំពាក់សម្ភារការិយាល័យជូនអង្គភាព ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណ ព្រឹទ្ធសភា ចំនួន១៩៣គ្រឿង/លើក។
- បានរៀបចំឯកសារស្នើជម្រះបញ្ជីរថយន្តព្រឹទ្ធសភា ចំនួន៣គ្រឿង។
- បានរៀបចំបញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋរបស់ព្រឹទ្ធសភា ទៅក្នុងប្រព័ន្ធ FMIS។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រ កម្ពុជា។
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ និង
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង ស្ថាប័ន ពាក់ព័ន្ធនានា។

### ៤.៣-ការងារសេវាច្បាប់៖

- បានទទួលអនុក្រឹត្យ សេចក្តីសម្រេច របាយការណ៍ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន ៨ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានទទួលសេចក្តីព្រាងច្បាប់ពីទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន៣ច្បាប់ និងពីរដ្ឋសភា ចំនួន២ច្បាប់ ព្រមទាំងបានថ្វាយ និងចែកគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា។
- បានធ្វើជំនួយស្មារតីដឹកនាំកិច្ចដំណើរការកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ សម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន៣លើក។
- បានធ្វើជំនួយស្មារតីជូនលេខាធិការសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
- បានធ្វើជំនួយស្មារតីជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រាយការណ៍ជូនអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២លើក។
- បានធ្វើដីកាបញ្ជូនសេចក្តីសម្រេចស្តីពី ការចាត់តាំងក្រុមសមាជរដ្ឋសភា និងព្រឹទ្ធសភា របស់សមាជិកព្រឹទ្ធសភា ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ។
- បានធ្វើបច្ចុប្បន្នភាពកម្មវិធីចុះបេសកកម្មរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣។
- បានធ្វើតារាងទិន្នន័យ ស្ថិតិរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងចំនួនក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥។
- បានធ្វើបច្ចុប្បន្នភាពបញ្ជីសេចក្តីព្រាងច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់តាមឆ្នាំ និងតាមនីតិកាល។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ និងធ្វើរបាយការណ៍ជូនគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៣៣៦លើក។
- បានទាក់ទងជាមួយរដ្ឋបាលរាជធានី ខេត្ត ដើម្បីត្រៀមរៀបចំជូនថ្នាក់ដឹកនាំ អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រមូលព័ត៌មានថ្មីៗ ដើម្បីធ្វើបច្ចុប្បន្នភាពក្រុមប្រឹក្សាខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់ ចំនួន១៩លើក និង
- បានសម្រួលដំណើរការបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប២ឆ្នាំ ទទួលការតែងតាំងថ្មី និងចប់មុខតំណែង ចាប់ពីថ្ងៃទី១៧ ខែមករា ដល់ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥ ចំនួន ៦១នាក់។

### ៤.៤-ការងារស្រាវជ្រាវ៖

- បានស្រាវជ្រាវ និងកសាងជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន៣ច្បាប់ រួមមាន៖
    - សេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។
    - សេចក្តីព្រាងច្បាប់ស្តីពី ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក និង
    - សេចក្តីព្រាងច្បាប់ស្តីពី ផលផល។

- បានស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីស្តីពី " ប្រមូលព័ត៌មាន និងការប្រឈមសំខាន់ៗ នៅថ្នាក់មូលដ្ឋាន ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត " ជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦។
- បានតាមដាន និងសិក្សាលើព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និងរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។
- បានតាមដានការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី៖
  - ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ និង
  - ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។
- បន្តសិក្សាស្រាវជ្រាវអំពី៖
  - វឌ្ឍនភាពនៃការអនុវត្តរបស់រាជរដ្ឋាភិបាលពីការធ្វើវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យនានា និង
  - ថវិការដ្ឋ ថវិកាថ្នាក់ក្រោមជាតិ តុល្យការថវិកា ការខ្ចី និងស្ថានភាពបំណុលសាធារណៈ និងហានិភ័យសារពើពន្ធ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ការប្រៀបធៀបបរិបទប្រទេសនៅក្នុងតំបន់អាស៊ាន។
- បានធ្វើបទបង្ហាញអំពីឯកសារជំនួយស្មារតីនៃការសិក្សាស្រាវជ្រាវលើសេចក្តីព្រាងច្បាប់ ចំនួន២ច្បាប់ ជូនសមាជិកព្រឹទ្ធសភាក្រុមទី៤។
- បានរៀបចំប្រមូលទិន្នន័យថវិកាមូលនិធិ ថ្នាក់ឃុំ សង្កាត់ រយៈពេល១០ឆ្នាំ។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានចងក្រងឯកសារយុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន ២១៣ ព័ត៌មាន។
- បានស្រង់ឯកសារពីក្នុងរាជកិច្ច និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ១-៦ ឆ្នាំ២០២៤) និង
- បានបញ្ចូលទិន្នន័យថវិកាចំណូល-ចំណាយក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុ និងសេដ្ឋកិច្ច (TOFE) ប្រចាំខែ ក្នុងឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៤.៨-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន៣១លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងសកម្មភាពការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធ Facebook, Instagram, X (Former Twitter), Youtube និងTiktok ចំនួន១,៦៧៦លើក។
- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា

និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២៩៩សកម្មភាព។
- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃ ចំនួន១,២២៣ ប្រធានបទ។
- បានអញ្ជើញអ្នកសារព័ត៌មាននៃទូរទស្សន៍ជាតិកម្ពុជា ចូលយកព័ត៌មាន ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាងថ្នាក់ដឹកនាំព្រឹទ្ធសភា ជាមួយភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងកិច្ចប្រជុំសំខាន់ៗ របស់ព្រឹទ្ធសភា ចំនួន៩លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការ ទាំង១០ ក្រុមភូមិភាគទាំង៨ និងក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅខ្លោងទ្វារធំព្រឹទ្ធសភា ចំនួន ១១លើក។
- បានរៀបចំផលិត និងផ្សព្វផ្សាយៈ
    - ប្រតិទិនការងារ ឆ្នាំ២០២៥ ចំនួន៤៥០ក្បាល និង
    - ទស្សនាវដ្តីព្រឹទ្ធសភាប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ ចំនួន៦០០ក្បាល។
- បានស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយព័ត៌មានស្តីពី បច្ចេកវិទ្យាឌីជីថល ចំនួន៨៣ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ និងជួសជុល ឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញ បច្ចេកវិទ្យាព័ត៌មាន ចំនួន១៥២គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធសំឡេង ប្រព័ន្ធមេក្រូហ្វូន ប្រព័ន្ធរូបភាព ប្រព័ន្ធកាមេរ៉ា និង ប្រព័ន្ធប្រជុំនិម្មិត ឬប្រព័ន្ធប្រជុំពីចម្ងាយ( Digital ) ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន៣៤លើក។
- បានទទួលឯកសារ ទស្សនាវដ្តី សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន៨ក្បាល ព្រមទាំង បានចុះបញ្ជីសៀវភៅ ចំនួន៦ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារ ជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ដោយគិតត្រឹមខែកុម្ភៈ ឆ្នាំ២០២៥ បានចំនួន៧,៦៣០ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០២៣នាក់ និង
- បានផ្សព្វផ្សាយឯកសារ និងសៀវភៅដែលមាននៅក្នុងបណ្ណាល័យព្រឹទ្ធសភា ក្នុងផេក TikTok របស់ បណ្ណាល័យព្រឹទ្ធសភា។

**៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិៈ**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និង ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៣៤លើក។
- បានរៀបចំសារលិខិតជូនពរ លិខិតរំលែកទុក្ខ និងកន្ត្រកផ្កា ជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា ចំនួន៦លិខិត និងចំនួន២កន្ត្រក។

- បានបកប្រែឯកសារ រៀបចំលិខិតឆ្លើយតបជាភាសាអង់គ្លេស ឯកសារជំនួយស្មារតី ព្រមទាំងបានរៀបចំបែបបទ និងកសាងឯកសារនានា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២១ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយ "ព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥" ចំនួន ១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៤ច្បាប់ និង
- បានតុបតែងលម្អបំភ្លឺភ្លើងពណ៌នៅខាងមុខស្ថាប័នព្រឹទ្ធសភា និងចងបដា ពាក្យស្លោក ក្នុងឱកាសនៃពិធីបុណ្យមាឃបូជា។

### ៩.៧-ការងារអគ្គាធិការដ្ឋាន៖

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែកុម្ភៈ ឆ្នាំ២០២៥។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃ ចំនួន៤០លើក ប្រចាំសប្តាហ៍ ចំនួន៤លើក និងប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែមីនា ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន២ច្បាប់៖
  - ១-សេចក្តីព្រាងច្បាប់ស្តីពី ជលផល និង
  - ២-សេចក្តីព្រាងច្បាប់ស្តីពី ការទទួលខុសត្រូវលើផលិតផលមានវិការៈ។
- ត្រៀមរៀបចំកិច្ចប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសិក្សាលើ

សេចក្តីព្រាងច្បាប់ ចំនួន២ច្បាប់ និង

- បន្តពិភាក្សារៀបចំសមាជរដ្ឋសភា និងព្រឹទ្ធសភា។

## ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា របស់រាជរដ្ឋាភិបាល ក្នុងរយៈពេលវិស្សមកាល៣ខែ ចាប់ពីថ្ងៃទី៦ ខែមករា ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ខុទ្ទកាល័យថ្នាក់ដឹកនាំទាំង៣ ការិយាល័យជំនួយការគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមសមាជិកាព្រឹទ្ធសភា ត្រៀមធ្វើរបាយការណ៍ស្តីពី លទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភានីតិកាលទី៥ នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ និង
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ត្រៀមចុះជួបសំណេះសំណាលជាមួយអាជ្ញាធរ ដើម្បីឈ្វេងយល់អំពីការអនុវត្តតួនាទី ភារកិច្ច ក្នុងការអនុវត្តច្បាប់ និងការផ្តល់សេវាសាធារណៈ នៅខេត្តប៉ៃលិន។

## ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា ពិធីសាសនា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ត្រៀមផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា រួមមាន៖
    - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ត្រៀម៖

      ១/ ចុះប្រាស្រ័យទាក់ទងជាមួយអង្គបោះឆ្នោត តាមដាន និងវាយតម្លៃពីដំណោះស្រាយបញ្ហាប្រឈម និងសំណូមពរនានា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២

      ២/ បន្តស្វែងយល់បញ្ហាប្រឈម សំណូមពរ របស់អាជ្ញាធរខណ្ឌទាំង១៤ និង

      ៣/ ចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលទាំង១០៥ ផ្សព្វផ្សាយច្បាប់ថ្មីៗ ដែលព្រឹទ្ធសភាបានអនុម័ត និងបច្ចុប្បន្នភាពសភាពការណ៍ នៅខណ្ឌច្បារអំពៅ ខណ្ឌដង្កោ ខណ្ឌមានជ័យ និងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
    - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងទី៥ ត្រៀមចុះជួបសំណេះសំណាលជាមួយអង្គបោះឆ្នោត ដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពង្រឹងការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការផ្តល់សេវាសាធារណៈ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារអភិវឌ្ឍមូលដ្ឋាន ព្រមទាំងចូលរួមដោះស្រាយ និងនាំយកយោបល់ សំណូមពរ ឬបញ្ហានានា ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នៅខេត្តត្បូងឃ្មុំ និងខេត្តកែប។

- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ត្រៀមចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពិភាក្សាការងារ ជាមួយអាជ្ញាធរដែនដី ដើម្បីឈ្វេងយល់អំពីបញ្ហាប្រឈម សំណូមពរ ដំណោះស្រាយ ការអភិវឌ្ឍមូលដ្ឋាន និងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន នៅស្រុកល្វាឯម ស្រុកខ្សាច់កណ្ដាល ស្រុកមុខកំពូល ក្រុងអរិយក្សត្រ និងក្រុងតាខ្មៅ ខេត្តកណ្ដាល និង
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ និងទី៧ ត្រៀមចុះឈ្វេងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅបន្ត តាមដានវឌ្ឍនភាពការងារ ផ្សព្វផ្សាយច្បាប់ថ្មីៗ ដែលព្រឹទ្ធសភាបានអនុម័ត និងធ្វើបច្ចុប្បន្នភាពសភាពការណ៍ នៅខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តកំពង់ឆ្នាំង។

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជួបសំណេះសំណាលជាមួយគណៈប្រតិភូជាតិនារី ក្នុងឱកាសទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៥។
- ត្រៀមរៀបចំពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៤ ឆ្នាំ២០២៥។
- ត្រៀមរៀបចំចាត់ចែងបញ្ជូនសារលិខិតជូនពរ គោរពជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨។
- ត្រៀមរៀបចំពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន និងសិស្ស និស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា៖
  - អញ្ជើញបំពេញទស្សនកិច្ចការងារ នៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។
  - អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកិច្ចការសភានៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងវៀងចន្ទន៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង
  - អញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៥០ និងកិច្ចប្រជុំពាក់ព័ន្ធ នៅប្រទេសអ៊ូសបេគីស្ថាន។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងផលិតឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមបើកវគ្គបណ្ដុះបណ្ដាលស្តីពី ជំនាញឌីជីថលចាំបាច់ (Essential Digital Skills) នៅវិទ្យាស្ថានឌីជីថល(IDG) នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថល (CADT)។

- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី ជំនាញកត់ត្រា និងជំនាញសំខាន់ៗជាច្រើនទៀត។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនក្នុងអំឡុងពេលចន្លោះសម័យប្រជុំឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តការចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

ខែកុម្ភៈ ជាខែទី២ នៃវិស្សមកាលរយៈពេលបីខែរបស់ព្រឹទ្ធសភា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា និងក្រុមយន្តការនានា បានបង្កើនសកម្មភាពការងារក្នុងការបំពេញមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាងតាមរយៈការចុះមូលដ្ឋាន នៅរាជធានី និងតាមបណ្តាខេត្ត និងជំនួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ យ៉ាងមមាញឹក ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ទិសដៅ និងបញ្ហាប្រឈម ការផ្សព្វផ្សាយច្បាប់ ការអនុវត្តច្បាប់ និងគោលនយោបាយនានា របស់រាជរដ្ឋាភិបាល។

ក្នុងបរិបទនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំ និងយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ ជូនសមាជិកព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនសម្រេចបានលទ្ធផលល្អ។

ក្រៅពីការផ្តល់សេវានៅមូលដ្ឋាន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏បានផ្តល់សេវាលើមុខងារនីតិកម្ម ដោយរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងរៀបចំដំណើរបំពេញបេសកកម្មក្រៅប្រទេស ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជាមួយភ្ញៀវជាតិ និងអន្តរជាតិ បានដោយរលូន ទទួលបានលទ្ធផលផ្លែផ្កា ជាគុណប្រយោជន៍ជូនជាតិមាតុភូមិ។

ថ្ងៃ ៨ ១ ខែ ពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំកុល**